**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សាលក្រមព្រហ្មទណ្ឌ
លេខ: ០៥៥ (ឧ)
ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣

*តាងនាមប្រជារាស្ត្រខ្មែរ*

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ដោយមានសមាសភាព:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោក [redacted] មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៨១៥ អក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted]វណ្ណ: ភេទស្រី អាយុ ៤៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មេផ្ទះ ទីកន្លែងកំណើតនៅ[redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]សុខៃ (រស់), ម្តាយឈ្មោះ [redacted]វណ្ណី (រស់) ប្តីឈ្មោះ [redacted] នឿន (រស់) មានកូនចំនួន ០៤នាក់។ (ក្រៅឃុំ)

២-ឈ្មោះ [redacted]សុវណ្ណនីតា ភេទស្រី អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើត និងមានទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]នឿន (រស់) ម្តាយឈ្មោះ [redacted]វណ្ណ: (រស់) ប្តីឈ្មោះ បាន មាស មានកូនចំនួន ០២នាក់។(ក្រៅឃុំ)

ពីបទ៖ **ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ** ប្រព្រឹត្តនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥២៣ នៃក្រមព្រហ្មទណ្ឌ។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ មានឈ្មោះ [redacted]វណ្ណ: និងឈ្មោះ សៅ សុវណ្ណនីតា បានឃុបឃិតគ្នាធ្វើឯកសារទិញលក់ដីមួយកន្លែង ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១០ ដោយមានចុះហត្ថលេខាដោយមេឃុំបន្ទាយដែក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុខហេង ដោយពុំឲ្យឈ្មោះ [redacted] សុខហេង បានដឹងឡើយ ។ លុះរហូតដល់អំឡុងឆ្នាំ២០២១ ឈ្មោះ [redacted] សុខហេង ក៏បានទទួលដំណឹងនេះហើយឈ្មោះ [redacted] សុខហេង ក៏បានប្តឹងចូលមកសាលាដំបូងខេត្តកណ្តាល ដើម្បីសុំចេញដីកាសម្រេចក្សាការពារហាមឃាត់ឈ្មោះ [redacted] វណ្ណ: និង



Scanned with CamScanner

ឈ្មោះ [redacted] សុវណ្ណនីតា សាលាដំបូងខេត្តកណ្ដាល ក៏បានចេញដីកាសម្រេចរក្សាការពារលេខ: ៥៣ ដកសរ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ តាមការប្ដឹងរបស់ឈ្មោះ [redacted] សុខហេង និងបានអនុវត្តត្រឹមត្រូវតាមច្បាប់រួចហើយ តែឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុវណ្ណនីតា មិនបានអនុវត្តតាមសេចក្ដីសម្រេចនេះទេ គឺឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុវណ្ណនីតា នៅតែធ្វើសកម្មភាពសាងសង់សំណង់ផ្សេងៗ នៅលើដីនោះថែមទៀតផង ដោយមិនខ្វល់ពីការសម្រេចរបស់តុលាការនោះទេ ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខ: ១២៣៣ ដកសព ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១៣០៨ ដកចត ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

-ដីកាដំណោះស្រាយលេខ: ១២៦៥ ដកដស ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

## នាពេលសវនាការ

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណនីតា បានឆ្លើយថាៈ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ខ្លួនបានទិញដីមួយកន្លែងពីឈ្មោះ [redacted] សោភា ដែលមានទំហំទទឹង ១០ម៉ែត្រ និងបណ្ដោយ ៧,៥ ម៉ែត្រ ដែលមានព្រំប្រទល់ខាងជើងទល់នឹងចំណីផ្លូវ ខាងត្បូងទល់នឹងឈ្មោះ [redacted] តាំងគួន ខាងកើតទល់នឹងឈ្មោះ [redacted] វណ្ណៈ និងខាងលិចទល់នឹងឈ្មោះ [redacted] ពិសិដ្ឋ ដីនេះមានទីតាំងស្ថិតនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដោយទិញក្នុងតម្លៃ ១៥០០០(មួយម៉ឺនបួនពាន់ដុល្លារអាមេរិក)។ នៅពេលខ្លួនទិញដីពីឈ្មោះ [redacted] សោភា នោះគឺបានធ្វើលិខិតផ្ទេរសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដោយមានការទទួលស្គាល់ពីលោកមេភូមិ និងលោកមេឃុំ។ ក្រោយពីទិញដីនេះហើយ ខ្លួនពុំបានធ្វើអ្វីនៅលើដីនេះទេ។ លុះដល់ឆ្នាំ២០២១ ខ្លួនបានចាក់ដី និងធ្វើរោងនៅលើដីនោះ ហើយនៅពេលធ្វើរោងនោះ ក៏មានអាជ្ញាភូមិឃុំ បានមកហាមឃាត់ នៅពេលនោះខ្លួនបានផ្អាកធ្វើរោងនោះចាប់ពីពេលនោះមករហូតមកដល់សព្វថ្ងៃនេះ ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានឆ្លើយថាៈ នៅថ្ងៃខែឆ្នាំមិនចាំ មានឈ្មោះ [redacted] សោភា ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សុខហេង និងឪពុកក្មេក បានលក់ដីមួយកន្លែងទំហំ ១០ម៉ែត្រ និងបណ្ដោយ ៧ម៉ែត្រ ដែលនៅជាប់ផ្លូវជាតិលេខ១ បានលក់មកឲ្យកូនរបស់ខ្លួនឈ្មោះ [redacted] សុវណ្ណនីតា ។ នៅពេលលក់ ទិញដីនោះ គឺបានធ្វើលិខិតស្នាមត្រឹមត្រូវ ដោយមានការទទួលដោយអាជ្ញាធរមូលដ្ឋានភូមិ ឃុំ។ នៅពេលលក់ ទិញដីនោះខ្លួនពុំបានផ្ដិតស្នាមមេដៃលើលិខិតស្នាមនោះទេ ចំណែកដីរបស់ខ្លួន គឺនៅជាប់ដីនោះដែរ។ លុះដល់ឆ្នាំ២០២១ កូនរបស់ខ្លួនឈ្មោះ [redacted] សុវណ្ណនីតា ក៏បានធ្វើរោងនៅលើដីនោះ ហើយនៅពេលធ្វើរោងនោះ គឺ អាជ្ញាធរបានមកហាមឃាត់ ហើយកូនរបស់ខ្លួនក៏ឈប់ធ្វើរោងនោះចាប់ពីពេលនោះមក ។

-អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខហេង** បានបញ្ជាក់ថាៈ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ មានឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] វណ្ណនីតា បានឃុបឃិតគ្នាធ្វើជាឯកសារទិញលក់ដីមួយកន្លែង ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ដោយមានហត្ថលេខាដោយមេឃុំបន្ទាយដែក ដែលជាកម្មសិទ្ធិរបស់ ខ្លួន ដោយខ្លួនពុំបានដឹងឡើយ លុះរហូតដល់អំឡុងឆ្នាំ២០២១ ខ្លួនក៏បានដឹងដំណឹងនេះ ខ្លួនក៏បានប្ដឹងសុំមក សាលាដំបូងខេត្តកណ្ដាល ឲ្យចេញដីកាសម្រេចរក្សាការពារលេខ ៥៣ ដកសរ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ តាមការប្ដឹងរបស់ខ្លួន និងបាន



Scanned with CamScanner

អនុវត្តត្រឹមត្រូវតាមច្បាប់រួចហើយ តែឈ្មោះ[redacted]វណ្ណៈ និងឈ្មោះ[redacted]សុវណ្ណនីតា មិនបានអនុវត្តតាមសេចក្តីសម្រេចនេះទេ គឺឈ្មោះនេះបានធ្វើសកម្មភាពសាងសង់សំណង់ផ្សេងៗ នៅលើដីនោះថែមទៀតផង ដោយមិនខ្វល់ពីការ សម្រេចរបស់តុលាការនេះទេ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សោភា បានបញ្ជាក់ថា៖ បន្ទាប់ពីប្តីខ្លួនឈ្មោះ[redacted] សុខហេង មានប្រពន្ធចុង ពេលនោះខ្លួនក៏បានដាក់ពាក្យលែងលះ មកសាលាសង្កាត់ស្ទឹងមានជ័យ ហើយការដោះស្រាយ ក៏បានចប់សព្វគ្រប់រួចរាល់ហើយ។ លុះក្រោយមកកូនរបស់ខ្លួនចេញទៅក្រៅប្រទេស ពេលនោះឈ្មោះ[redacted] សុខហេង ក៏បានដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តកណ្តាល ដោយឲ្យខ្លួនផ្តិតមេដៃឲ្យគាត់ ហើយគាត់ធានាចិញ្ចឹមកូនក្នុងមួយខែ ៧០០(ប្រាំពីររយដុល្លារអាមេរិក) ។ ក្រោយមកសាលាដំបូងខេត្តកណ្តាល ក៏បានចេញសាលក្រមឲ្យខ្លួនលែងលះជាមួយប្តីខ្លួន ។ ក្រោយពីកាលែងលះគ្នារួចឈ្មោះ[redacted] សុខហេង ក៏បានបោះបង់អាហារកិច្ចចិញ្ចឹមកូនមកឲ្យខ្លួន តែខ្លួនមិនបានដឹងថាឲ្យបានប៉ុន្មានឆ្នាំនោះទេ ដោយគាត់ឲ្យខានៗ លុះក្រោយមកគាត់ក៏បានឈប់បង់អាហារកិច្ចចិញ្ចឹមកូនតែម្តង ។ ដោយសារមានការខ្វះខាតក្នុងការចិញ្ចឹមកូន ខ្លួនក៏បានលក់ដីមួយកន្លែងឲ្យទៅឈ្មោះ [redacted] សុវណ្ណនីតា ដោយប្តីខ្លួនបានប្រាប់ខ្លួនឲ្យលក់។ ដីនោះខ្លួនលក់ក្នុងតម្លៃ ១៨០០០(មួយម៉ឺនដុល្លារអាមេរិក) ហើយប្រាក់ទាំងនេះ គឺនៅលើខ្លួនជាអ្នកទុកដាក់សម្រាប់ចិញ្ចឹមកូន ។

## ក្រោយពេលសួរដេញដោលនាពេលសវនាការ

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖ ឆ្លងកាត់តាមសវនាការរួចមក ឃើញថា ជនជាប់ចោទទាំងពីរនាក់បានឃុបឃិតគ្នាជាមួយ ភូមិ ឃុំ ក្នុងការលក់ ទិញ ដីរបស់កូនក្តីខ្លួន ហើយក្រោយមកកូនក្តីខ្លួនបានដឹង ក៏បានប្តឹងមកសាលាដំបូងខេត្តកណ្តាល ដើម្បីសុំដីការក្សាការពារ ។ ក្រោយពីសាលាដំបូងបានចេញដីកាសម្រេច និងបានអនុវត្តរួចហើយ ជនជាប់ចោទទាំងពីរនាក់ពុំបានគោរពតាមដីការសម្រេចនោះទេ ហេតុនេះស្នើសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការ ឃើញថា ពិតជាកើតមាននូវអង្គហេតុនៃអំពើ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ[redacted]វណ្ណៈ និងឈ្មោះ [redacted]សុវណ្ណនីតា ។ រក្សាការចោទប្រកាន់តាមដីការសន្និដ្ឋានស្ថាពរលេខ: ១២៣៣ ដកសព ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖ ឆ្លងកាត់តាមសវនាការរួចមក ចំពោះការចោទប្រកាន់មកលើកូនក្តីខ្លួនទាំងពីរនាក់ពីបទ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការប្រព្រឹត្តនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ គឺកូនក្តីខ្លួនពុំបានប្រព្រឹត្តនោះទេ ព្រោះថា កូនក្តីខ្លួនបានទិញដីពីឈ្មោះ[redacted]សោភា រួចមកបានធ្វើរបង និងសង់រោងដោយមិនទាន់ប្រក់ដំបូល និងជញ្ជាំងទេ ហើយក៏មានដីកាហាមឃាត់ពីសាលាដំបូងខេត្តកណ្តាល ។ ចាប់តាំងពីពេលនោះមកកូនក្តីខ្លួនក៏ឈប់បន្តការសាងសង់តែម្តង ហេតុនេះស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនពីបទល្មើសខាងលើ ចាប់ពីពេលនេះតទៅ ។

## យោងតាមការសួរដេញដោលនាពេលសវនាការ

-ក្រោយពីបានស្តាប់អំណានជនជាប់ចោទ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី។



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។
-ក្រោយពីបានពិនិត្យភស្តុតាងឯកសារទាំងអស់ក្នុងសំណុំរឿង។
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១-តាមអង្គហេតុបានបង្ហាញថា កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ស្ថិតនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុវណ្ណនីតា បានធ្វើសកម្មភាពមិនអនុវត្តតាមសេចក្តីសម្រេចតុលាការ ដោយតុលាការបានអនុវត្តនូវដីការសម្រេចរក្សាការពារ ពាក់ព័ន្ធនឹងការហាមឃាត់ការសាងសង់ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុវណ្ណនីតា បានឆ្លើយប្រហាក់ប្រហែលគ្នាថា៖ ក្រោយពីពួកខ្លួនបានទិញដីពីឈ្មោះ [redacted] សោភា រួចមក គឺបានធ្វើរបង តែក្រោយមកក៏មានការហាមឃាត់ពីអាជ្ញាធមិ ពួកខ្លួនក៏បានឈប់តាមការហាមឃាត់នោះ ។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការលើកយកមកពិចារណាបាន ព្រោះថា ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងជាឯកសារ ជាលិខិតបញ្ជាក់របស់ស្រុកកៀនស្វាយ ឃុំបន្ទាយដែក ដែលបានបញ្ជាក់ថា ជនជាប់ចោទជាប់បានធ្វើការសាងសងនៅមុនពេលការអនុវត្តដីការរក្សាការពារ ហើយបានក៏បានឈប់សាងសងនៅពេលដែលទទួលដំណឹងពីការអនុវត្តដីការក្សាការពារ ។

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខហេង បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានប្តឹងសុំមកសាលាដំបូងខេត្តកណ្តាល ឲ្យចេញដីកាសម្រេចរក្សាការពារលេខ ៥៣ ដកសរ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ និងបានអនុវត្តត្រឹមត្រូវតាមច្បាប់រួចហើយ ដោយឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុវណ្ណនីតា មិនបានអនុវត្តតាមសេចក្តីសម្រេចនេះទេ គឺបានធ្វើសកម្មភាពសាងសង់សំណង់ផ្សេងៗថែមទៀតដោយមិនខ្វល់ពីការសម្រេចរបស់តុលាការ ។ ឃើញថា ចម្លើយនេះគ្រាន់តែជាការអះអាងដាក់បន្ទុកមួយតែប៉ុណ្ណោះ ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលអាចឲ្យតុលាការលើកយកមកពិចារណាបានឡើយ ។

៤-ទាំងអំណានចម្លើយរបស់ជនជាប់ចោទ , អំណានរបស់ដើមបណ្តឹងរដ្ឋប្បវេណី , អំណានចម្លើយសាក្សី និងភស្តុតាងជាឯកសារពាក់ព័ន្ធនានា ដែលអាចកំណត់បានថាជនជាប់ចោទពុំមានការពាក់ព័ន្ធទៅនឹងការចោទប្រកាន់ពីបទ៖ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ តាមមាត្រា៥២៣ នៃក្រមព្រហ្មទណ្ឌឡើយ ។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺមិនមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសព្រហ្មទណ្ឌទេ ព្រោះថា ជនជាប់ចោទបានគោរពនូវការអនុវត្តពីដីការសម្រេចរបស់តុលាការនៅក្នុងការហាមឃាត់ ។

៦-ពុំមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ ដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] សុវណ្ណនីតា ដែលមានសាវតាជាតិដូចខាងលើ ពីបទ៖ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ ។

៧-គប្បីតុលាការសម្រេចឲ្យជនជាប់ចោទ រួចខ្លួនពីបទចោទប្រកាន់ ពីបទ៖ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៨-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាន៖ ស្នើសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។ គប្បីតុលាការពិចារណា ។

៩-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖រក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។ គប្បីតុលាការពិចារណា ។

១០-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន៖ ស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួន ។ គប្បីតុលាការពិចារណា ។

**សម្រេច**

១-ឲ្យជនជាប់ចោទ៖

១.១-ឈ្មោ[redacted]វណ្ណៈ ភេទស្រី អាយុ ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មេផ្ទះ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិខ្មុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ[redacted]សុខៃ (រស់), ម្តាយឈ្មោះ[redacted]វណ្ណី (រស់) ប្តីឈ្មោះ[redacted]នឿន (រស់) មានកូនចំនួន ០៤នាក់។ (ក្រៅឃុំ)

១.២- ឈ្មោះ[redacted]សុវណ្ណនីតា ភេទស្រី អាយុ ២៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើត និងមានទីលំនៅបច្ចុប្បន្ននៅភ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ[redacted]នឿន (រស់) ម្តាយឈ្មោះ[redacted]វណ្ណៈ (រស់) ប្តីឈ្មោះ បាន មាស មានកូនចំនួន ០២នាក់។(ក្រៅឃុំ)

រួចខ្លួនពីបទចោទប្រកាន់ ពីបទ៖ ធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ប្រព្រឹត្តនៅភូមិខ្មុំ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី តែចាត់ទុកថាជាចំពោះមុខ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃអង្គារ ៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧
ខេត្តកណ្តាល,ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃអង្គារ ៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧
ខេត្តកណ្តាល,ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner